**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តកណ្តាល**
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ០៩ អក ចុះថ្ងៃទី ០៣
ខែ មករា ឆ្នាំ ១៩៩៥

<u>សាលក្រម</u>
លេខ ៣០ "ព" ចុះថ្ងៃទី ០១
ខែ សីហា ឆ្នាំ ១៩៩៥

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកណ្តាល**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។ ដោយមាន :

**<u>ចៅក្រមជំនុំជំរះ</u>**
លោក [redacted] អនុប្រធានតុលាការខេត្តកណ្តាល
លោក [redacted] ចៅក្រមកម្មសិក្សា

**<u>តំណាងអយ្យការ</u>**
លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល

**<u>ក្រឡាបញ្ជីសវនាការ</u>**
លោក [redacted]

សាលក្រមនេះចូលជាសាលក្រមស្ថាពរនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ដោយគ្មានភាគីណាមួយប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** [redacted]

**បានឃើញ**
**ប្រធានតុលាការ** [redacted]

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះនៃតុលាការខេត្តកណ្តាល នាថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ដើម្បីជំនុំជំរះ :

១-ឈ្មោះ **ត ចល** ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា កើតនៅសង្កាត់លេខ ៥ ក្រុងភ្នំពេញ កិរិតវប្បធម៌មធ្យមសិក្សាប័ត្រភាគទី១ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៦ ផ្លូវលេខ ៣៣៦ សង្កាត់បឹងសាឡាង ក្រុងភ្នំពេញ របររកស៊ីនៅផ្ទះ ឪពុកឈ្មោះ **ត ច** (ស) ម្តាយឈ្មោះ **ល ចា** (ស) ប្រពន្ធឈ្មោះ **ស ភអ** ទោសពីមុន *គ្មាន* ។

ត្រូវបានជាប់ចោទពីបទ **ធ្វើមនុស្សឃាតដោយអចេតនា** នៅចំណុចភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកក្បៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

តាមរបាយការណ៍បូកសរុបរបស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល លេខ ៤០៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង យោងតាមដីកាសន្និដ្ឋានស្ថាពររបស់អយ្យការអមតុលាការខេត្តកណ្តាលលេខ ១២៤ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>** :

កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ វេលាម៉ោង ១១:០០ ឈ្មោះ **ត ចល** បានបើករថយន្តម៉ាកកាមីពណ៌ស ពាក់ផ្លាកលេខ ភ.៣២.១៥៨២១ រួមជាមួយគ្រួសារចេញពីភ្នំពេញទៅតាមផ្លូវជាតិលេខ ១ ក្នុងគោលបំណងទៅវត្តក្បៀនស្វាយក្រៅ ។ លុះបើកមក

ដល់ចន្លោះគីឡូម៉ែត្រលេខ ១១-១២ ស្ថិតនៅក្នុងភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល រថយន្ត នេះបានវ៉ារថយន្តមួយទៀត ហើយបានទៅប៉ះអ្នកថ្មើជើង ម្នាក់ឈ្មោះ រ សខ ភេទស្រី អាយុ ៥៣ឆ្នាំ មានទីលំនៅនៅ ភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដែលធ្វើដំណើរឆ្លងកាត់ថ្នល់ពីចិញ្ចើមផ្លូវខាងត្បូងមកជើង បណ្ដាលអោយរងរបួសជាទម្ងន់ ។ ឯរថយន្តបានបើករត់គេច តែត្រូវបាននគរបាលឃាត់ទាំងរថយន្ត និង អ្នកបើកបរ ចំណែកជនរងគ្រោះបានស្លាប់នៅពេលយកទៅមន្ទីរពេទ្យព្រះកុសមៈ ។

-បានឃើញកំណត់ហេតុពិនិត្យកន្លែងកើតហេតុ របស់នគរបាលស្រុកកៀនស្វាយ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ។

-បានឃើញគំនូសប្លង់កន្លែងកើតហេតុ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់នគរបាលស្រុកកៀនស្វាយ។

-បានឃើញរបាយការណ៍គ្រោះថ្នាក់ចរាចរ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់នគរបាល ស្រុកកៀនស្វាយ ។

-បានឃើញកំណត់ហេតុដកហូតវត្ថុតាង ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់នគរបាល ស្រុកកៀនស្វាយ ។

-បានឃើញលិខិតបញ្ជាក់មរណៈភាពឈ្មោះ រ សខ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់មន្ទីរពេទ្យ ព្រះកេតុមាលា លេខ ៧១/១៩៩៤ ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាងលេខ ០៣/៩៤ ចុះថ្ងៃទី ០២ ខែ មករា ឆាំ ១៩៩៥ របស់តុលាការ ខេត្តកណ្ដាល ។

-បានឃើញពាក្យសុំធានារបស់ឈ្មោះ ស អ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥ ។

-បានឃើញកំណត់ហេតុទទួលប្រាក់ធានារថយន្តលេខ ០១/១៩៩៥ របស់តុលាការខេត្តកណ្ដាល ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥ ។

-បានឃើញកំណត់ហេតុប្រគល់ និង ទទួលប្រាក់រវាងគ្រួសារជនល្មើស និង គ្រួសារជនរងគ្រោះ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ។

-បានឃើញកំណត់ហេតុប្រគល់រថយន្តម៉ាកកាម៉ារី ពណ៌ស ពាក់ផ្លាកលេខ ភ.៣២.១៥៨២១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥ របស់ក្រឡាបញ្ជីតុលាការខេត្តកណ្ដាល ។

-បានឃើញដីកាបញ្ជូនរឿងជំនុំជំរះលេខ ៨០ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់ចៅក្រមស៊ើប អង្កេត ។

-បានឃើញដីកាចាត់តាំងចៅក្រមលេខ ១១០ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់ប្រធានតុលាការ ខេត្តកណ្ដាល ។

## **នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ **ត ចឈ** បានឆ្លើយថា ថ្ងៃកើតហេតុនោះជាថ្ងៃបុណ្យអុំទូក ខ្លួនបានជិះរថយន្តម៉ាក តូយូតាកាមរីពណ៌ស ចេញពីផ្ទះនៅភ្នំពេញទៅកៀនស្វាយ ជាមួយប្រពន្ធ លុះជិះហួសផ្សារព្រែកឯងបន្តិច ខ្លួនក៏សុំវ៉ា រថយន្តមួយដែលនៅពីមុខ គេអោយវ៉ា លុះវ៉ាមិនទាន់ផុតផង ស្រាប់តែឃើញយាយម្នាក់រត់ឆ្លងថ្នល់ ហើយរេរាបំរុង ទៅមុខបន្តិចទៅក្រោយបន្តិច រថយន្តខ្លួនមកដល់ហ្វ៉ាំងមិនជាប់ព្រោះជិតពេកក៏ប៉ះគាត់ត្រង់កញ្ចក់មើលក្រោយ (ថ្កាល់ រថយន្ត) គាត់ក៏ដួល ខ្លួនក៏អែបបំរុងឈប់ ស្រាប់តែឃើញមនុស្សផ្អើលច្រើន និង មានសមត្ថកិច្ចផង ម្យ៉ាងខ្លាចគេវ៉ាយ

ធ្វើបាបខ្លួន១ក៏បើករត់មកដល់កែបថ្មី នគរបាលចាប់បានតែម្តង ។ ពេលប៉ះនោះគាត់មិនទាន់ស្លាប់ទេដឹកយកមកពេទ្យ បងខ្លួនទៅជួយមើល ហើយពេលគាត់ស្លាប់បងខ្លួនក៏ទៅជួយធ្វើបុណ្យដែរ ក្រោយពីធ្វើបុណ្យរួចមកខ្លួនបានសងសំណង ជំងឺចិត្តទៅគ្រួសារអ្នករងគ្រោះចំនួន ១៥០០ដុល្លាអាមេរិក គេក៏ទទួលយករួចហើយ ចំណែករថយន្តខ្លួនក៏បានទទួលយក មកប្រើប្រាសវិញហើយ ។

-ឈ្មោះ **ស ម** ជាកូនជនរង គ្រោះ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ថ្ងៃកើតហេតុនោះខ្លួនពុំបានដឹងទេ គឺនៅយាមប្រចាំការនៅមន្ទីរពេទ្យ លុះគេដឹកម្តាយទៅដល់ពេទ្យនៅម៉ោងប្រហែលជាង ១០ថ្ងៃ ទើបខ្លួនដឹងហើយឃើញរបួសគាត់ហូរឈាមត្រង់ក្បាលក្រោយចំហៀងខាងឆ្វេង លុះនៅម៉ោងប្រហែល ១០យប់គាត់ក៏ស្លាប់ ។ ខ្លួនពុំមានទាមទារសំណងជំងឺចិត្តអ្វីទៀតទេ ព្រោះម្ចាស់ឡានបានសងអោយខ្លួន ១៥០០ដុល្លាអាមេរិករួចហើយ ប៉ុន្តែខ្លួនសុំអោយម្ចាស់រថយន្ត ដែលបានប្រព្រឹត្តនោះត្រូវហ៊ានទទួលស្គាល់ពីកំហុសខ្លួនផង ។

-តាមអំណាចចម្លើយសាក្សីឈ្មោះ **ជ សម** ថា ខ្ញុំកំពុងអង្គុយលក់អ៊ីវ៉ាន់ចាប់ហួយ មានយាយណ្ហឹមកទិញបារី ខ្ញុំមួយរយរៀល រួចហើយឱ្យលុយខ្ញុំ ហើយខ្ញុំក៏ឱនសរសេរប្រហែលជា ០៥នាទី ស្រាប់តែលឺសួរផាំង ខ្ញុំងើបមុខឡើងឃើញ យាយនោះលើកដៃទាំងពីរឡើងលើនៅទន្ទឹមកាតាប៉ូមុខខាងស្តាំរថយន្តគាត់ក៏ដួលផ្ងារក្រោយ រថយន្តក៏បើករត់បាត់ទៅ ហើយយកអ្នករងគ្រោះទៅពេទ្យ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ត មឈ** ពីបទប្រព្រឹត្តអំពើមនុស្សឃាតដោយចេតនា កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ហើយសំរេចដកល់ដីកាសន្និដ្ឋានស្ថាពរលេខ ១២៤ ចុះថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់អយ្យការទុកជាបានការពេញលេញ និង សំណូមពរផ្តន្ទាទោស តាមមាត្រា ៤០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានស្តាប់ចម្លើយជនជាប់ចោទ

-បានស្តាប់ចម្លើយគ្រួសារជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី

-បានស្តាប់ចម្លើយសាក្សី

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**<u>តុលាការខេត្តកណ្តាល</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ឈ្មោះ **ត មឈ** ពិតជាបានបើកបររថយន្តម៉ាកតូយូតាកាមរី ពាក់ផ្លាកលេខ ភ.ព.២ ១៥៨២១ ហើយបង្កអោយមានគ្រោះថ្នាក់ចរាចរកាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ នៅចំណុចភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល បណ្តាលអោយមនុស្សស្លាប់ប្រាកដមែន ។

-ឈ្មោះ **ត មឈ** ដែលបើករថយន្តនេះមានប័ណ្ណបើកបរត្រឹមត្រូវហើយ ចំណែកឯរថយន្តម៉ាកតូយូតាកាមរី ក៏មានលក្ខណៈបច្ចេលទេសល្អ ព្រមទាំងមានប័ណ្ណសំគាល់រថយន្តត្រឹមត្រូវទៀតផង ។

-ជនរងគ្រោះឈ្មោះ **វ សខ** ភេទស្រី អាយុ ៥៨ឆ្នាំ ដែលត្រូវឈ្មោះ **ត មឈ** បើកបររថយន្តបុក កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ពិតជាបានបាត់បង់ជីវិតពិតប្រាកដមែន ។

-តាមគំនូសគំរោងនៃគ្រោះថ្នាក់ចរាចរ និង តាមសេចក្តីសន្និដ្ឋានរបស់ស្នងការនគរបាលខេត្តកណ្តាល ហើយនឹងអនុវត្តតាមច្បាប់ស្តីពីចរាចរផ្លូវគោកជំពូក ២ និង ជំពូក ៣ ឃើញថា ទាំងអ្នករងគ្រោះ ទាំងអ្នកបើកបររថយន្តសុទ្ធ

តែមានកំហុសទាំងសងខាង ។

-អំពើដែលឈ្មោះ **ត ចឈ** បើកបររថយន្តទៅបង្កគ្រោះថ្នាក់ដល់ឈ្មោះ **ន សខ** បណ្តាលអោយស្លាប់នេះពុំមែនធ្វើឡើងដោយចេតនាឡើយ គឺដោយអចេតនាទាំងស្រុង ព្រោះឈ្មោះនេះកំពុងម៉ើកបរក្នុងល្បឿនមួយ ដើម្បីជែងរថយន្តមួយទៀត ស្រាប់តែជនរងគ្រោះរត់ឆ្លងកាត់ផ្លូវពីមុខរថយន្តក៏បណ្តាលអោយគ្រោះថ្នាក់កើតឡើងតែម្តង ។

-ទោះបីអំពើរបស់ជនជាប់ចោទធ្វើឡើងដោយអចេតនាក៏ដោយ ក៏កំហុសក្នុងការបើកបរដោយមិនប្រុងប្រយ័ត្នរបស់ជននេះមិនអាចជៀសគេចអោយផុតពីការទទួលខុសត្រូវខាងផ្លូវច្បាប់ឡើយ ។

-ពិតជាមានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ **ត ចឈ** ពីបទប្រព្រឹត្តអំពើមនុស្សឃាតដោយអចេតនា កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ។ នៅចំណុចភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រាកដមែន ។

-អំពើរបស់ជនជាប់ចោទរូបនេះ ត្រូវតែផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បើពិនិត្យលើអំពើរបស់ជនជាប់ចោទរូបនេះឃើញថា ពិតជាត្រូវទទួលទោសគុកប្រាកដណាស់ ប៉ុន្តែបើពិនិត្យលើកត្តាសត្យានុម័តវិញឃើញថា កំហុសនេះក៏បណ្តាលមកពីជនរងគ្រោះដែរ ។

-គ្រួសារជនជាប់ចោទ និង ជនជាប់ចោទបានជួយចេញសោហ៊ុយព្យាបាល និង ធ្វើបុណ្យសពព្រមទាំងបានសងសំណងជំងឺចិត្តរួចហើយ ។

-ឈ្មោះ **ស ម** ជាកូនជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានព្រមព្រៀងទទួលសំណងជំងឺចិត្តជាប្រាក់ ១៥០០ដុល្លាអាមេរិក ពីជនល្មើសរួចហើយនោះ បញ្ហានេះតុលាការពុំលើកយកមកពិចារណាឡើយ ។

-រថយន្តម៉ាកតូយូតាកាមរី ពាក់ផ្លាកលេខ ភ.ព.២.១៥៨២១ ម្ចាស់រថយន្តបានទទួលយកវិញហើយនោះ បញ្ហានេះតុលាការពុំលើកយកមកពិចារណាឡើយ ។

**<u>ហេតុដូច្នេះសំរេច</u> :**

១-**<u>ផ្តន្ទាទោស</u> :**

-ឈ្មោះ **ត ចឈ** ឈ្មោះក្រៅគ្មាន ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ តែទោសនេះត្រូវព្យួរ ដោយមានរយៈពេលសាកល្បង ០៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះ ។

ពីបទ : ប្រព្រឹត្តអំពើមនុស្សឃាតដោយអចេតនា កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ នៅចំណុចភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤០ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្តីនេះ ព្រះករុណា នៃព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រមអោយសំរេចតាមសាលក្រមនេះ នឹង អោយអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ជួយផ្តល់កំលាំង ក្នុងការអនុវត្តន៍

សាលក្រម បើមានសំណួមពរត្រឹមត្រូវតាមច្បាប់ ។

*កណ្តាល, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៥*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្តកណ្តាល**

[redacted]